# ប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវា

## 14.សេចក្តីណែនាំ

14.A.1 ផ្នែក C នៃច្បាប់ស្តីពីការអប់រំដល់ជនមានពិការភាព (IDEA) ត្រូវបានរៀបចំឡើងដោយសភាឱ្យក្លាយជាប្រព័ន្ធផ្តល់សេវាកម្មអន្តរភ្នាក់ងារស៊ីសង្វាក់គ្នាពេញលេញសម្រាប់ទារក និងកុមារតូចៗដែលមានពិការភាព ។ សភាទទួលស្គាល់ថាមានកម្មវិធីផ្សេងៗដែលមានស្រាប់រួចហើយដែលបម្រើដល់ប្រជាជនទាំងនេះ ហើយផ្នែក C ត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធដើម្បីសម្របសម្រួល ទូទាំងកម្មវិធីទាំងនេះ។ ជាលទ្ធផលការផ្តល់ប្រាក់សម្រាប់ផ្នែក C ត្រូវបានរៀបចំឡើងដើម្បីប្រើប្រភពផ្តល់ប្រាក់ថ្នាក់មូលដ្ឋាន រដ្ឋ និងសហព័ន្ធ រួមមានការធានារ៉ាប់រងឯកជន និងរដ្ឋ។ ដោយសារមិនមានការផ្តល់ប្រាក់រដ្ឋគ្រប់គ្រាន់ ដើម្បីចេញថ្លៃធានារ៉ាប់រងការចំណាយលើអន្តរាគមន៍បឋមវ័យទាំងអស់ មិនមែនសេវាកម្មអន្តរាគមន៍បឋមវ័យទាំងអស់សុទ្ធតែអាចត្រូវបានផ្តល់ដោយការចំណាយរបស់រដ្ឋឡើយ។ គ្រួសារទាំងឡាយត្រូវបានគេរំពឹងទុកថានឹងចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុដល់កម្មវិធីកូនៗរបស់ពួកគេ។ ការរំពឹងទុកនេះត្រូវបានបំពេញដោយការផ្តល់សិទ្ធិទទួលបានការធានារ៉ាប់រង/ការថែទាំសុខភាព និង Apple Health for Kids/Medicaid សម្រាប់សេវាកម្មអន្តរាគមន៍បឋមវ័យទាំងឡាយណាដែលស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសាររបស់ ESIT។

14.A.2 វាគឺជាភារកិច្ចរបស់កម្មវិធីគាំទ្របឋមវ័យសម្រាប់ទារក និងកុមារតូចៗ (ESIT) ដែលត្រូវប្រើធនធានទាំងអស់នេះ ដើម្បីបម្រើដល់ទារក និងកុមារតូចៗដែលមានពិការភាព និងក្រុមគ្រួសាររបស់ពួកគេឱ្យបានចំនួនច្រើនបំផុត។ វាក៏ជាភារកិច្ចរបស់ ESIT ដែលត្រូវធានាថាធនធានទាំងនេះត្រូវបានប្រើ ដើម្បីផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យដែលគ្រប់គ្រាន់សម្រាប់ផ្តល់អត្ថប្រយោជន៍ខាងលូតលាស់ដល់កុមារ។ ដើម្បីឱ្យ ESIT រក្សាបាននូវលក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលទូលំទូលាយ ចាំបាច់ត្រូវប្រើប្រភពផ្តល់ប្រាក់ដែលមានទាំងអស់ រួមមានការធានារ៉ាប់រងរដ្ឋ ការធានារ៉ាប់រងឯកជន និងថ្លៃឈ្នួលនានា។

14.A.3 បើសិនជាចាំបាច់ត្រូវបង្ការការពន្យារពេលក្នុងការផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យសមស្របដល់កុមារ ឬគ្រួសាររបស់កុមារ ESIT អាចប្រើមូលនិធិដែលនៅក្រោមផ្នែក C នៃ IDEA ដើម្បីទូទាត់ឱ្យអ្នកផ្តល់សេវាកម្ម ឬមុខងារដែលត្រូវបានអនុញ្ញាត (រួមមានសេវាកម្មសុខភាព ដូចបានកំណត់នៅក្នុង ៣៤ CFR §៣០៣.១៦ [ប៉ុន្តែមិនមែនជាសេវាកម្មវេជ្ជសាស្ត្រ]) មុខងារនៃប្រព័ន្ធស្វែងរកកុមារដូចដែលបានរៀបរាប់នៅក្នុង ៣៤ CFR §§៣០៣.១១៥ តាមរយៈ ៣០៣.១១៧ និង §§៣០៣.៣០១ តាមរយៈ ៣០៣.៣២០ និងការវាយតម្លៃ និងការប៉ាន់ប្រមាណនៅក្នុង §៣០៣.៣២១) ការបង់សងដែលមិនទាន់បានសម្រេចពីភ្នាក់ងារ ឬអង្គភាពដែលទទួលខុសត្រូវចុងក្រោយបង្អស់ចំពោះការទូទាត់។



### សូមទាក់ទង៖


**The Washington State Department of Children, Youth & Families Early Support for Infants and Toddlers Program**
ប្រអប់សំបុត្រ 40970
Olympia, WA 98504-0970
លេខទូរស័ព្ទឥតគិតថ្លៃ៖
1-866-482-4325
www.dcyf.wa.gov


---

បើលោកអ្នកចង់បានសេចក្តីចម្លងនៃឯកសារនេះ ជាភាសា ឬទម្រង់ផ្សេងទៀត សូមទាក់ទងផ្នែកទំនាក់ទំនងសមាជិក DCYF តាមលេខ (1-800-723-4831 | 360-902-8060, ConstRelations@dcyf.wa.gov)។


DCYF PUBLICATION FS_0033 |
DEL 11-019 CA (01-2020) Cambodian

## 14.B គោលនយោបាយ

14.B.1 **មុខងារ និងសេវាកម្មដែលផ្តល់តាមការចំណាយរបស់រដ្ឋ**

(a) យោងតាម ៣៤ CFR ៖៣០៣.៥២១(b) (២០១១) IDEA ខាងក្រោម សេវាកម្ម និងមុខងារនៅក្នុងផ្នែក C ត្រូវតែបានផ្តល់ជូនតាមការចំណាយរបស់រដ្ឋតាមរយៈកម្មវិធីគាំទ្របឋមវ័យស្រមាប់ទារក និងកុមារតូចៗ (ESIT) និងអ្នកផ្តល់សេវារបស់ខ្លួនដែលអាចនឹងមិនគិតថ្លៃឈ្នួលអ្វីព្រីគ្រួសារឡើយ៖

(1) ការអនុវត្តលក្ខខណ្ឌតម្រូវនៃការស្វែងរកកុមារក្នុង ៖៖៣០៣.៣០១ តាមរយៈ ៣០៣.៣០៣។

(2) ការវាយតម្លៃ និងការប៉ាន់ប្រមាណ យោងតាម ៖៣០៣.៣២០ និងមុខងារផ្សេងៗទាក់ទងនឹងការប៉ាន់ប្រមាណ និងការវាយតម្លៃនៅក្នុង ៖៣០៣.១៣(b)។

(3) បណ្តាសេវាកម្មសម្របសម្រួលសេវាកម្ម (ការសម្របសម្រួលធនធានគ្រួសារ) ដូចបានកំណត់នៅក្នុង ៖៖៣០៣.១៣(b)(១១) និង ៣០៣.៣៣។

(4) សកម្មភាពសម្របសម្រួល និងរដ្ឋបាលទាក់ទងនឹង —

(i) ការអភិវឌ្ឍ ការត្រួតពិនិត្យ និងការវាយតម្លៃនៃបណ្តា IFSPs និង IFSPs បណ្តោះអាសន្នស្របតាម ៖៖៣០៣.៣៤២ តាមរយៈ ៣០៣.៣៤៥ និង

(ii) ការអនុវត្តនៃផ្នែករង E ការការពារជានីតិវិធី និងសមាសធាតុផ្សេងទៀតនៃប្រព័ន្ធសេវាកម្មអន្តរាគមន៍បឋមវ័យទូទាំងរដ្ឋនៅក្នុង ផ្នែករង D នៃ ៣៤ CFR ៖៣០៣។

(b) **ការធានា៖** យោងតាម ៣៤ CFR៖៣០៣.៥២១(a)(៤)(ii) បើសិនជាគ្រួសារបំពេញតាមនិយមន័យ "អសមត្ថភាពទូទាត់" នោះរាល់សេវាកម្មក្នុងផ្នែក C ដែលបានកំណត់នៅលើ IFSP របស់កូនពួកគេ នឹងត្រូវបានផ្តល់ជូនដោយមិនគិតថ្លៃចំពោះគ្រួសារនោះ។ លើសពីនេះ ភាពអសមត្ថភាពក្នុងការទូទាត់របស់គ្រួសារ នឹងមិនបណ្តាលឱ្យមានការពន្យារពេល ឬការបដិសេធនៃសេវាកម្មក្នុងផ្នែក C ទេ។

14.B.2 **មុខងារ និងសេវាកម្មអាស្រ័យលើការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ** ( FCP )

(a) យោងតាម ៣៤ CFR ៖៣០៣.៥២១(b) មុខងារ និងសេវាកម្ម ដូចខាងក្រោមដែលអាស្រ័យលើការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ ហើយដែលការទូទាត់រួម ការធានារ៉ាប់រងរួម ការកាត់កង ឬថ្លៃឈ្នួលអាចត្រូវបានគិតព្រីគ្រួសារ៖

(1) ឧបករណ៍បច្ចេកវិទ្យាជំនួយ

(2) សេវាកម្មបច្ចេកវិទ្យាជំនួយ

(3) សេវាកម្មសោតទស្សន៍

(4) ការប្រឹក្សាយោបល់

(5) សេវាកម្មសុខភាព

(6) សេវាកម្មថែទាំ

(7) សេវាកម្មអាហារូបត្ថម្ភ

(8) ការព្យាបាលដោយវិជ្ជាជីវៈ

(9) ការព្យាបាលដោយចលនា

(10) សេវាកម្មខាងចិត្តសាស្ត្រ

(11) សេវាកម្មសង្គមកិច្ច

(12) សេវាកម្មរោគសាស្ត្រភាសា-ការនិយាយ

(b) **ការធានា៖** យោងតាម ៣៤ CFR §៣០៣.៥២១ (a) (៤)(iii) គ្រួសារទាំងឡាយនឹងមិនត្រូវបានគិតថ្លៃលើសពីតម្លៃជាក់ស្តែងនៃសេវាកម្មអន្តរាគមន៍ក្នុងផ្នែក C ដែលអាស្រ័យតាមការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ (ដែលរួមបញ្ចូលក្នុងចំនួនទឹកប្រាក់ណាមួយដែលទទួលបានពីប្រភពផ្តល់ប្រាក់ដទៃទៀតដែលត្រូវបានចាត់ចែងសម្រាប់ការទូទាត់ចំពោះសេវាកម្មនោះ)។

14.B.3 **បណ្តាប្រភពផ្តល់ប្រាក់ដែលត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធថ្លៃឈ្នួល និងការទូទាត់របស់រដ្ឋ** Washington **សម្រាប់សេវាកម្មអន្តរាគមន៍បឋមវ័យអាស្រ័យតាមការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ**

វាគឺជាការរំពឹងទុកថា បើសិនជាភាពអសមត្ថភាពក្នុងការទូទាត់មិនត្រូវបានកំណត់ទេ គ្រួសារទាំងអស់ដែលទទួលសេវាកម្មអាស្រ័យតាមការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ នឹងចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុចំពោះសេវាកម្មកូនរបស់ពួកគេតាមរយៈការប្រើអត្ថប្រយោជន៍ធានារ៉ាប់រងរដ្ឋ អត្ថប្រយោជន៍ធានារ៉ាប់រងឯកជន ឬតាមរយៈការទូទាត់ថ្លៃឈ្នួល។ ជាលទ្ធផល ប្រភពផ្តល់ប្រាក់ទាំងឡាយខាងក្រោមត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវារបស់ ESIT៖

(a) ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពរដ្ឋ (Apple Health for Kids/Medicaid)

(b) ធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន

(c) ថ្លៃឈ្នួល

14.B.4 **ព័ត៌មានអំពីចំណូល និងចំណាយគ្រួសារ**

(a) មុនពេលចេញវិក្កយបត្រធានារ៉ាប់រងឯកជន ឬរដ្ឋ គ្រួសារទាំងឡាយនឹងត្រូវបានផ្តល់ជូននូវប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវា ESIT ។ គ្រួសារទាំងឡាយត្រូវបានស្នើឱ្យបំពេញនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន សេចក្តីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងឯកជន/រដ្ឋ និងទម្រង់បញ្ជាក់ព័ត៌មានអំពីចំណូល និងចំណាយគ្រួសារ តាមការសម្រួល។

(b) អ្នកសម្របសម្រួលធនធានគ្រួសារ(FRC) របស់គ្រួសារទាំងឡាយនឹងជួយគ្រួសារនានាក្នុងការត្រួតពិនិត្យ និងបំពេញនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន សេចក្តីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងឯកជន/រដ្ឋ និងទម្រង់បញ្ជាក់ព័ត៌មានអំពីចំណូល និងចំណាយគ្រួសារតាមការសម្រួល។

(c) សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន សេចក្តីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងឯកជន/រដ្ឋ និងទម្រង់បញ្ជាក់ព័ត៌មានប្រាក់ចំណូលនិងចំណាយគ្រួសារនឹងត្រូវបានដាក់ទៅ FRC ដែលត្រូវបានចាត់តាំងសម្រាប់គ្រួសារនោះ។

(d) បើសិនជាព័ត៌មានអំពីចំណូល និងចំណាយគ្រួសារឃើញថាប្រាក់ចំណូលប្រចាំឆ្នាំដែលបានលៃលកហើយមានចំនួនក្រោម ២០០% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ (FPL) ផ្អែកលើទំហំគ្រួសារ គ្រួសារនោះនឹងមិនត្រូវបានតម្រូវឱ្យបង់លើការចំណាយរួមលើការធានារ៉ាប់រង ការធានារ៉ាប់រងរួម ការកាត់កងធានារ៉ាប់រង ឬថ្លៃឈ្នួលប្រចាំខែទេ។ មូលនិធិទីភ្នាក់ងារផ្សេងទៀត ឬមូលនិធិរបស់ផ្នែក C ដែលជាអ្នកបង់ប្រាក់ចុងក្រោយបំផុត អាចត្រូវបានប្រើដើម្បីរ៉ាប់រងថ្លៃចំណាយទាំងនេះ។

(e) បើសិនជាព័ត៌មានអំពីចំណូល និងចំណាយគ្រួសារឃើញថាប្រាក់ចំណូលប្រចាំឆ្នាំដែលបានលៃលកហើយមានចំនួនលើស ២០០% នៃ FPL ដែលផ្អែកលើទំហំគ្រួសារ បើអាចអនុវត្តបាន នោះគ្រួសារនោះនឹងត្រូវបានតម្រូវឱ្យបង់លើការចំណាយរួមលើការធានារ៉ាប់រង ការធានារ៉ាប់រងរួម ការកាត់កងធានារ៉ាប់រង ឬថ្លៃឈ្នួលប្រចាំខែ។

14.B.5 **ការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពរដ្ឋ** ( Apple Health for Kids/Medicaid )

(a) យោងតាម ៣៤ CFR§៣០៣.៥២០(a)(២)(i) គ្រួសារទាំងឡាយដែលបានចុះឈ្មោះនៅក្នុងកម្មវិធីអន្តរាគមន៍បឋមវ័យនៃ ESIT នឹងមិនត្រូវបានតម្រូវឲ្យចុះឈ្មោះប្រើ ឬចុះឈ្មោះនៅក្នុង Apple Health for Kids/Medicaid ជាលក្ខខណ្ឌសម្រាប់កូនរបស់ពួកគេដើម្បីទទួលសេវាកម្មអន្តរាគមន៍បឋមវ័យក្នុងផ្នែក C ទេ។

(b) យោងតាម ៣៤ CFR§៣០៣.៥២០(a)(៣) គ្រួសារទាំងឡាយនឹងត្រូវបានផ្តល់ជូននូវប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវា ESIT មុនពេលប្រើអត្ថប្រយោជន៍ឬការធានារ៉ាប់រងរដ្ឋរបស់ឪពុកម្តាយ ឬកូន សម្រាប់សេវាកម្មក្នុងផ្នែក C។

(c) យោងតាម ៣៤ CFR§៣០៣.៥២០(a)(២)(ii) អ្នកផ្តល់អន្តរាគមន៍បឋមវ័យនឹងទទួលការយល់ព្រមពីគ្រួសារបើសិនជាការទទួល Apple Health for Kids/Medicaid ធ្វើឱ្យមានករណីណាមួយខាងក្រោម៖

(1) ការថយចុះនូវការធានារ៉ាប់រងពេញមួយជីវិតដែលមាន ឬអត្ថប្រយោជន៍ដែលត្រូវបានធានារ៉ាប់រងផ្សេងទៀតសម្រាប់កូន ឬឪពុកម្តាយដែលស្ថិតក្រោមកម្មវិធីនោះ

(2) ធ្វើឱ្យឪពុកម្តាយរបស់កុមារទូទាត់សម្រាប់បណ្តាសេវាកម្មដែល ដែលមិនដូច្នោះទេត្រូវបានទូទាត់ដោយកម្មវិធីអត្ថប្រយោជន៍សាធារណៈ ឬការធានារ៉ាប់រងរដ្ឋ

(3) បណ្តាលឱ្យមានការកើនឡើងនូវបុព្វលាភរ៉ាប់រង ឬការបញ្ឈប់នូវអត្ថប្រយោជន៍ ឬការធានារ៉ាប់រងរដ្ឋណាមួយសម្រាប់កុមារ ឬឪពុកម្តាយ ឬ

(4) ហានិភ័យនៃការបាត់បង់សិទ្ធិទទួលសម្រាប់កុមារ ឬឪពុកម្តាយរបស់កុមារ ចំពោះការអនុគ្រោះផ្អែកលើសហគមន៍ និងផ្ទះ ដែលផ្អែកលើការចំណាយដែលទាក់ទងនឹងសុខភាពជាសរុប។

(d) យោងតាម ៣៤ CFR §៣០៣.៥២០(b)(១) នៅពេលគ្រួសារទាំងឡាយមានទាំង Apple Health សម្រាប់កម្មវិធី Kids/Medicaid និងការធានារ៉ាប់រងឯកជន អ្នកផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យត្រូវតែទទួលការយល់ព្រមពីឪពុកម្តាយសម្រាប់៖

(1) ការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់គ្រួសារ ដើម្បីទូទាត់សម្រាប់ការផ្តល់ជូនដំបូងនៃសេវាកម្មអន្តរាគមន៍បឋមវ័យដែលមាននៅក្នុង IFSP

(2) ការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន ដើម្បីទូទាត់សម្រាប់ការកើនឡើងនូវភាពញឹកញាប់ រយៈពេល ថេរវេលា ឬ ភាពខ្លាំងក្លានៃសេវាកម្មនៅក្នុង IFSP របស់កុមារ។

(e) **ការធានា៖** យោងតាម ៣៤ CFR §៣០៣.៥២១(a)(៤)(iv) បណ្តាគ្រួសារដែលមានអត្ថប្រយោជន៍ ឬការធានារ៉ាប់រងរដ្ឋនឹងមិនត្រូវបានគិតថ្លៃច្រើនជាងបណ្តាគ្រួសារដែលគ្មានអត្ថប្រយោជន៍ ឬការធានារ៉ាប់រង ឬការធានារ៉ាប់រងឯកជនដោយមិនសមាមាត្រគ្នានោះទេ។

(f) អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យនឹង៖

(1) យោងតាម ៣៤ CFR §§៣០៣.៤១៤ and ៣០៣.៥២០(a)(៣)(i) ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ្រួសារដែលបានចុះឈ្មោះក្នុង Apple Health for Kids/Medicaid ដែលប្រាប់ពួកគេថាព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួននឹងត្រូវបានបង្ហាញទៅ Apple Health for Kids/Medicaid ក្នុងគោលបំណងចេញវិក្កយបត្រសម្រាប់សេវាកម្មអន្តរាគមន៍បឋមវ័យដែលបានផ្តល់ទៅឱ្យកូនរបស់ពួកគេ។

(2) យោងតាម ៣៤ CFR §៣០៣.៥២០(a)(៣)(iii) ផ្តល់ដំណឹងដល់គ្រួសារទាំងឡាយថាពួកគេមានសិទ្ធិដកការយល់ព្រមរបស់ពួកគេចំពោះការបង្ហាញព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់គោលបំណងចេញវិក្កយបត្រនៅពេលណាក៏បាន។

(3) យោងតាម ៣៤ CFR §៣០៣.៥២០(a)(៣)(iv) ផ្តល់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីប្រភេទចំណាយទូទៅដែលគ្រួសារអាចនឹងមាន ដោយសារការប្រើប្រាស់ Apple Health for Kids/Medicaid ។

(g) អ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យនឹងមិនទូទាត់ចំណាយលើបុព្វលាភរ៉ាប់រងសម្រាប់ Apple Health for Kids/Medicaid ទេ។

(h) យោងតាម ៣៤ CFR §៣០៣.៥២០(a)(២)(iii) បើសិនជាឪពុកម្តាយ មិនផ្តល់ការយល់ព្រមក្នុងការចុះឈ្មោះ ឬទទួល Apple Health for Kids/Medicaid ទេ នោះអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យនៅតែត្រូវផ្តល់ជូនបណ្តាសេវាកម្មអន្តរាគមន៍បឋមវ័យក្នុងផ្នែក C ទាំងនោះនៅលើ IFSP ដែលឪពុកម្តាយបានផ្តល់ការយល់ព្រម។ កង្វះការយល់ព្រមសម្រាប់ការប្រើ Apple Health for Kids/Medicaid មិនអាចត្រូវបានប្រើដើម្បីពន្យារពេល ឬបដិសេធសេវាកម្មណាមួយនៅក្រោមផ្នែកនេះចំពោះកុមារ ឬគ្រួសារទេ។

(i) នៅពេលសិទ្ធិទទួល Apple Health for Kids/Medicaid មិនអាចបញ្ជាក់បាន ឬក៏គ្រួសារបានបដិសេធមិនផ្តល់ព័ត៌មានអំពីចំណូល និងចំណាយគ្រួសារ នោះគ្រួសារនោះនឹងត្រូវបានតម្រូវឱ្យអនុវត្តតាមប្រព័ន្ធបណ្តូទូទាត់ប្រាក់ និងថ្លៃសេវារបស់រដ្ឋ Washington ។

14.B.6 **ការប្រើប្រាស់ការធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន**

(a) យោងតាម ៣៤ CFR ទ៣០៣.៥២០(b)(១)(iii) គ្រួសារទាំងឡាយនឹងត្រូវបានផ្តល់ជូន នូវប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវា ESIT មុនពេលប្រើការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់ឪពុកម្តាយ ឬកូនដើម្បីបង់ប្រាក់ស្រមាប់សេវាកម្មក្នុងផ្នែក C។

(b) យោងតាម ៣៤ CFR ទ៣០៣.៥២០(b)(១)(i) អ្នកផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យត្រូវតែទទួលការយល់ព្រមពីឪពុកម្តាយស្រមាប់៖

(1) ការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់គ្រួសារ ដើម្បីទូទាត់សម្រាប់ការផ្តល់ជូនដំបូងនៃសេវាកម្មអន្តរាគមន៍បឋមវ័យដែលមាននៅក្នុង IFSP

(2) ការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន ដើម្បីទូទាត់សម្រាប់ការកើនឡើងនូវភាពញឹកញាប់ រយៈពេល ថេរវេលា ឬ ភាពខ្លាំងក្លានៃសេវាកម្មនៅក្នុង IFSP របស់កុមារ។

(c) **ការធានា៖** យោងតាម ៣៤ CFR ទ៣០៣.៥២១(a)(៤)(iv) បណ្តាគ្រួសារដែលមានការធានារ៉ាប់រងឯកជន នឹងមិនត្រូវបានគិតថ្លៃច្រើនជាងបណ្តាគ្រួសារដែលគ្មានអត្ថប្រយោជន៍ ឬការធានារ៉ាប់រងរដ្ឋ ឬការធានារ៉ាប់រងឯកជនដោយមិនសមាមាត្រគ្នានោះទេ។

(d) យោងតាម ៣៤ CFR ទ៣០៣.៥២០(b)(១)(ii) អ្នកផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យនឹងផ្តល់ជូនសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីប្រភេទចំណាយទូទៅដែលគ្រួសារអាចនឹងមានដោយសារការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន ដូចជា៖

(1) ការទូទាត់រួម ការធានារ៉ាប់រងរួម បុព្វលាភរ៉ាប់រង ឬការកាត់កង ឬការចំណាយរយៈពេលវែងផ្សេងទៀត ដូចជាការបាត់បង់អត្ថប្រយោជន៍ដោយសារចំនួនអតិបរមានៃការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពប្រចាំឆ្នាំ ឬមួយជីវិត ក្រោមបណ្ណធានារ៉ាប់រងស្រមាប់កុមារ ឪពុកម្តាយ ឬសមាជិកគ្រួសាររបស់កុមារ

(2) សក្តានុពលដែលការប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់គ្រួសារ អាចជះឥទ្ធិពលអវិជ្ជមានដល់ភាពអាចប្រើបាននៃធានារ៉ាប់រងសុខភាពដល់កុមារដែលមានពិការភាព ឪពុកម្តាយ ឬសមាជិកគ្រួសាររបស់កុមារ ដែលត្រូវបានរ៉ាប់រងក្រោមបណ្ណនោះ ហើយការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាព អាចត្រូវបានបញ្ឈប់ដោយសារការប្រើប្រាស់បណ្ណធានារ៉ាប់រងដើម្បីទូទាត់ស្រមាប់សេវាកម្មអន្តរាគមន៍បឋមវ័យក្នុងផ្នែក C ឬ

(3) សក្តានុពលដែលបុព្វលាភសម្រាប់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាព អាចត្រូវបានរងផលប៉ះពាល់ដោយសារការប្រើប្រាស់ការធានារ៉ាប់រងឯកជនដើម្បីទូទាត់ស្រមាប់សេវាកម្មអន្តរាគមន៍បឋមវ័យ។

(e) អ្នកផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យ នឹងមិនបង់ថ្លៃបុព្វលាភរ៉ាប់រងសម្រាប់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពទេ។

(f) យោងតាម ៣៤ CFR ទ៣០៣.៥២០(a)(២)(iii) បើសិនជាឪពុកម្តាយ មិនផ្តល់ការយល់ព្រមឲ្យប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជននោះទេ នោះអ្នកផ្តល់សេវាអន្តរាគមន៍បឋមវ័យនៅតែត្រូវផ្តល់ជូនបណ្តាសេវាកម្មអន្តរាគមន៍បឋមវ័យក្នុងផ្នែក C ទាំងនោះនៅលើ IFSP ដែលឪពុកម្តាយបានផ្តល់ការយល់ព្រម។ កង្វះការយល់ព្រម អាចនឹងមិនត្រូវបានប្រើដើម្បីពន្យារពេល ឬបដិសេធសេវាកម្មណាមួយចំពោះកុមារ ឬគ្រួសារឡើយ។ នៅពេលឪពុកម្តាយ ឬគ្រួសារ មិនផ្តល់ការយល់ព្រមឲ្យ ប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់ពួកគេ គ្រួសារនឹងត្រូវបានតម្រូវឲ្យអនុវត្តតាមប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវារបស់រដ្ឋ Washington ។

(g) សម្រាប់គ្រួសារទាំងអស់ដែលត្រូវបានគិតប្រាក់ជាលក្ខណៈការទូទាត់រួម ការធានារ៉ាប់រងរួម ឬការកាត់កង មូលនិធិទីភ្នាក់ងារផ្សេងទៀត ដែលរួមទាំងអ្នកបង់ប្រាក់ក្នុងផ្នែក C នៃមូលនិធិចុងក្រោយបង្អស់ អាចត្រូវបានប្រើដើម្បីរ៉ាប់រងថ្លៃចំណាយទាំងនេះ។

(h) គ្រួសារដែលហួសពេល ៩០ ថ្ងៃ នៅមិនទាន់បង់ប្រាក់ចំពោះការទូទាត់រួម ការធានារ៉ាប់រងរួម ឬការកាត់កង នោះនឹងទទួលរងការព្យួរ សេវាកម្មអាស្រ័យលើការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ រហូតដល់ពេលបង្កើតផែនការទូទាត់រួចរាល់។ វានឹងកើតឡើងបន្ទាប់ពីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គ្រួសារ អ្នកសម្របសម្រួលធនធានគ្រួសារ និងអ្នកផ្តល់សេវាកម្ម។

### 14.B.7 **និយមន័យអំពីសមត្ថភាពទូទាត់របស់ឪពុកម្ដាយ**

ESIT បានកំណត់ថា **សមត្ថភាពទូទាត់** ជាប្រាក់ចំណូលសរុបប្រចាំឆ្នាំដែលបានលៃលកហើយរបស់គ្រួសារដែលស្មើ ឬខ្ពស់ជាង ២០០% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ (FPL) ដែលត្រូវបានលៃលកសម្រាប់ការចំណាយឥតសំណងដែលអនុគ្រោះឲ្យបាន ដែលលើសពី ១០%។

(a) ព័ត៌មានអំពីចំណូល និងចំណាយគឺត្រូវការដើម្បីកំណត់ពីសមត្ថភាពទូទាត់ថ្លៃឈ្នួលប្រចាំខែរបស់គ្រួសារ។

(b) ការចំណាយឥតសំណងដែលអនុគ្រោះឲ្យបាន រួមមាន៖ ការចំណាយលើផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ រួមមានបុព្វលាភរ៉ាប់រង ការកាត់កង ការចំណាយរួម និងការធានារ៉ាប់រងរួម

  (1) ការចំណាយលើផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ រួមមានបុព្វលាភរ៉ាប់រង ការកាត់កង ការចំណាយរួម និងការធានារ៉ាប់រងរួម

  (2) ការព្យាបាលសុខភាពផ្លូវចិត្តមិនត្រូវបានធានារ៉ាប់រងទេ

  (3) ការថែទាំសុខភាពតាមផ្ទះដែលផ្ដល់ដោយទីភ្នាក់ងារសុខភាពតាមផ្ទះដែលមានអាជ្ញាបណ្ណ

  (4) ការទូទាត់សម្រាប់អាហារកិច្ច/ការគាំពារកុមារ

  (5) ការចំណាយលើការថែទាំកុមារដែលកើតមាននៅពេលឪពុកម្ដាយធ្វើការ ឬទៅសាលារៀន។

(c) មុនពេលចេញវិក្កយបត្រចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពរដ្ឋ ឬការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន គ្រួសារនឹងត្រូវបានស្នើសុំឲ្យពិនិត្យ និងបំពេញសេចក្ដីជូនដំណឹងមុនជាលាយលក្ខណ៍អក្សរ សេចក្ដីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងរដ្ឋ និង/ឬ ការធានារ៉ាប់រងឯកជន និងបែបបទផ្ទៀងផ្ទាត់ចំណូល និងចំណាយ ដែលនឹងរួមមានដូចខាងក្រោម៖

  (1) ព័ត៌មានអំពីចំណូល និងចំណាយ

  (2) សេចក្ដីយល់ព្រមបញ្ចេញព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន និង

  (3) សេចក្ដីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងរដ្ឋ និង/ឬឯកជន។

(d) ឋានៈនៃសមត្ថភាពទូទាត់របស់គ្រួសារត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពយ៉ាងហោចណាស់មួយឆ្នាំម្ដង ឬឆាប់ជាងនេះ បើសិនជាគ្រួសារស្នើសុំ។

### 14.B.8 **និយមន័យអំពីអសមត្ថភាពទូទាត់របស់ឪពុកម្ដាយ**

ESIT បានកំណត់ថា **សមត្ថភាពទូទាត់** ជាប្រាក់ចំណូលសរុបប្រចាំឆ្នាំដែលបានលៃលកហើយរបស់គ្រួសារដែលស្មើ ឬក្រោម ២០០% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ (FPL) ដែលត្រូវបានលៃលកសម្រាប់ការចំណាយឥតសំណងដែលអនុគ្រោះឲ្យបាន ដែលលើសពី ១០%។

(a) ព័ត៌មានអំពីចំណូល និងចំណាយគឺត្រូវការដើម្បីកំណត់ពីសមត្ថភាពទូទាត់របស់គ្រួសារ។

(b) ការចំណាយមិនឲ្យសងវិញដែលអាចអនុញ្ញាតបានរួមមាន៖

  (1) ការចំណាយលើផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ រួមមានបុព្វលាភរ៉ាប់រង ការកាត់កង ការចំណាយរួម និងការធានារ៉ាប់រងរួម

  (2) ការព្យាបាលសុខភាពផ្លូវចិត្តមិនត្រូវបានធានារ៉ាប់រងទេ

  (3) ការថែទាំសុខភាពតាមផ្ទះដែលផ្ដល់ដោយទីភ្នាក់ងារសុខភាពតាមផ្ទះដែលមានអាជ្ញាបណ្ណ

  (4) ការទូទាត់សម្រាប់អាហារកិច្ច/ការគាំពារកុមារ

  (5) ការចំណាយលើការថែទាំកុមារដែលកើតមាននៅពេលឪពុកម្ដាយធ្វើការ ឬទៅសាលារៀន។

(c) មុនពេលចេញវិក្កយបត្រចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពរដ្ឋ ឬការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជន គ្រួសារនឹងត្រូវបានស្នើសុំឲ្យពិនិត្យ និងបំពេញសេចក្ដីជូនដំណឹងមុនជាលាយលក្ខណ៍អក្សរ សេចក្ដីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងសាធារណៈ និង/ឬ ធានារ៉ាប់រងឯកជន និងបែបបទផ្ទៀងផ្ទាត់ចំណូល និងចំណាយ ដែលនឹងរួមមានដូចខាងក្រោម៖

  (1) ព័ត៌មានអំពីចំណូល និងចំណាយ

  (2) សេចក្ដីយល់ព្រមបញ្ចេញព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន និង

  (3) សេចក្ដីយល់ព្រមប្រើប្រាស់ការធានារ៉ាប់រងរដ្ឋ និង/ឬឯកជន។

(d) ឋានៈនៃសមត្ថភាពទូទាត់របស់គ្រួសារត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពយ៉ាងហោចណាស់មួយឆ្នាំម្តង ឬឆាប់ជាងនេះ បើសិនជាគ្រួសារស្នើសុំ។

## 14.B.9 ថ្លៃឈ្នួល

(a) យោងតាម ៣៤ CFR ទ៣០៣.៥២១ សម្រាប់គ្រួសារដែលត្រូវបានកំណត់ថាមាន "សមត្ថភាពទូទាត់" ESIT បានបង្កើតថ្លៃឈ្នួលប្រចាំខែសម្រាប់សេវាកម្មអន្តរាគមន៍បឋមវ័យអាស្រ័យលើការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ នៅពេលមានកត្តាណាមួយខាងក្រោមនេះ៖

(1) គ្រួសារបដិសេធប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់ពួកគេ

(2) គ្រួសារបដិសេធការប្រើប្រាស់ Apple Health for Kids/Medicaid របស់ពួកគេ ការធានារ៉ាប់រង/ការរ៉ាប់រងថែទាំសុខភាពសាធារណៈ និងមានចំណូលប្រចាំឆ្នាំដែលបានលៃលកហើយស្មើ ឬលើស ២០០% FPL ឬ

(3) គ្រួសារមិនមាន Apple Health for Kids/Medicaid ឬការធានារ៉ាប់រង/ការរ៉ាប់រងថែទាំសុខភាពឯកជន ។

(b) គ្រួសារដែលបដិសេធមិនផ្តល់ព័ត៌មានអំពីចំណូល និងចំណាយ នឹងត្រូវទូទាត់ថ្លៃឈ្នួលប្រចាំខែក្នុងកម្រិតខ្ពស់បំផុតផ្អែកលើទំហំគ្រួសារ ដែលរួមបញ្ចូលក្នុងចំនួនទឹកប្រាក់ដែលទទួលបានពីប្រភពផ្តល់ប្រាក់រដ្ឋដទៃទៀតដែលទទួលបានក្នុងការទូទាត់សម្រាប់សេវាកម្មទាំងនោះ។

(c) កាលវិភាគថ្លៃឈ្នួលប្រចាំខែ ត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍ណែនាំអំពីកម្រិតភាពក្រីក្ររបស់សហព័ន្ធ (FPL) ហើយនឹងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

(d) ប្រសិនបើគ្រួសារផ្តល់ការយល់ព្រមឲ្យប្រើប្រាស់ការធានារ៉ាប់រងរដ្ឋ និង/ឬ ឯកជនរបស់ពួកគេសម្រាប់ការផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យដែលអាស្រ័យលើការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសារ នោះពួកគេនឹងមិនបង់ថ្លៃឈ្នួលប្រចាំខែទេ។

(e) សម្រាប់គ្រួសារដែលបានចុះឈ្មោះក្នុង Apple Health for Kids/Medicaid បំពេញតាមនិយមន័យអំពី "អសមត្ថភាពទូទាត់" និងបដិសេធមិនប្រើប្រាស់ប្រភពផ្តល់ប្រាក់នេះសម្រាប់ទូទាត់សេវាកម្មអន្តរាគមន៍បឋមវ័យក្នុងផ្នែក C នោះសេវាកម្មក្នុងផ្នែក C ទាំងអស់ដែលត្រូវបានកំណត់អំពី IFSP របស់កូនពួកគេ នឹងត្រូវបានផ្តល់ជូនដោយមិនគិតថ្លៃ។ លើសពីនេះ ភាពអសមត្ថភាពក្នុងការទូទាត់របស់គ្រួសារ នឹងមិនបណ្តាលឱ្យមានការពន្យារពេល ឬការបដិសេធសេវាកម្មក្នុងផ្នែក C ទេ។

(f) សម្រាប់គ្រួសារដែលមិនបានចុះឈ្មោះចូលក្នុង Apple Health for Kids/Medicaid និងបានបដិសេធមិនផ្តល់ព័ត៌មានអំពីចំណូល និងចំណាយ នឹងត្រូវបានគិតថ្លៃឈ្នួលប្រចាំខែនៅកម្រិតខ្ពស់បំផុតផ្អែកលើទំហំគ្រួសារ ដែលរួមបញ្ចូលក្នុងចំនួនទឹកប្រាក់ដែលទទួលបានពីប្រភពផ្តល់ប្រាក់រដ្ឋដទៃទៀតដែលទទួលបានក្នុងការទូទាត់សម្រាប់សេវាកម្មទាំងនោះ។

(g) គ្រួសារដែលបដិសេធមិនប្រើប្រាស់ការចេញថ្លៃធានារ៉ាប់រង/ការធានារ៉ាប់រងថែទាំសុខភាពឯកជនរបស់ពួកគេ និងដែលបានផ្តល់ព័ត៌មានអំពីចំណូល និងចំណាយ នឹងត្រូវបានគិតថ្លៃឈ្នួលប្រចាំខែដោយផ្អែកលើទំហំគ្រួសារ និងចំណូលប្រចាំឆ្នាំដែលបានលៃលកហើយ។

(h) គ្រួសារអាចស្នើសុំឲ្យមានការកំណត់ឡើងវិញនូវថ្លៃឈ្នួលប្រចាំខែរបស់ពួកគេរាល់ពេលមានការផ្លាស់ប្តូរទំហំគ្រួសារ ចំណូល និង/ឬចំណាយ។ ការកែសម្រួលណាមួយទៅលើថ្លៃឈ្នួលប្រចាំខែ នឹងកើតមានបន្ទាប់ពីបានធ្វើការកំណត់ឡើងវិញ។

(i) គ្រួសារដែលហួសពេល ៩០ ថ្ងៃ នៅមិនទាន់បង់ថ្លៃឈ្នួលប្រចាំខែរបស់ពួកគេ នោះទទួលរងការព្យួរ សេវាកម្មសម្រាប់កូនរបស់ពួកគេអាស្រ័យលើការចូលរួមក្នុងថ្លៃចំណាយនៃគ្រួសាររហូតដល់ពេលបង្កើតផែនការទូទាត់ដែលអាចទទួលយកបានរួចរាល់។ វានឹងកើតឡើងបន្ទាប់ពីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គ្រួសារ អ្នកសម្របសម្រួលធនធានគ្រួសារ និងអ្នកផ្តល់សេវាកម្ម។

### 14.B.10 លក្ខខណ្ឌតម្រូវនៃការការពារតាមនីតិវិធី

(a) យោងតាម ៣៤ CFR ទ៣០៣.៥២១(e) គ្រួសារនឹងត្រូវបានផ្តល់ជូននូវសេចក្តីចម្លងអំពីប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវា ដែលរៀបរាប់លម្អិតអំពីការការពារតាមនីតិវិធីដែលទាក់ទងនឹង៖

(1) ការដាក់កំហិតឲ្យបង់ថ្លៃឈ្នួល

(2) ការកំណត់របស់រដ្ឋអំពីសមត្ថភាព ឬអសមត្ថភាពទូទាត់របស់ឪពុកម្តាយ និង

(3) ការចេញវិក្កយបត្រធានារ៉ាប់រងរដ្ឋ ឬឯកជន។

(b) ឪពុកម្តាយមានសិទ្ធិ៖

(1) ចូលរួមក្នុងការសម្រុះសម្រួលយោងតាម ៣៤ CFR ទ៣០៣.៤៣១

(2) ស្នើសុំឲ្យមានសវនាការអំពីដំណើរការត្រឹមត្រូវយោងតាម ៣៤ CFR ទ៣០៣..៤៣៦ ឬ ទ៣០៣.៤៤១ ដែលអាចអនុវត្តបាន

(3) ដាក់បណ្តឹងតវ៉ាថ្នាក់រដ្ឋយោងតាម ៣៤ CFR ទ៣០៣.៤៣៤ និង/ឬ

(4) នីតិវិធីផ្សេងទៀតដែលត្រូវបានបង្កើតឡើងដោយរដ្ឋ ដើម្បីពន្លឿនដំណោះស្រាយនៃការទាមទារប្រាក់កាក់

(c) យោងតាម ៣៤ CFR ទ៣០៣.៥២១(e)(២)(i) អ្នកផ្តល់សេវា ESIT នឹងផ្តល់សេចក្តីចម្លងជាលាយលក្ខណ៍អក្សរអំពីប្រព័ន្ធប័ណ្ណទូទាត់ប្រាក់ និងថ្លៃសេវារបស់ខ្លួនទៅឲ្យឪពុកម្តាយពេលមានការស្នើសុំ៖

(1) សេចក្តីយល់ព្រមសម្រាប់ការផ្តល់សេវាកម្មអន្តរាគមន៍បឋមវ័យ ត្រូវបានទទួលនៅឯកិច្ចប្រជុំស្តីពីផែនការសេវាកម្មគ្រួសារផ្ទាល់ខ្លួន (IFSP) និង

(2) សេចក្តីយល់ព្រមសម្រាប់ការប្រើប្រាស់ការធានារ៉ាប់រងឯកជនដើម្បីទូទាត់សេវាកម្មក្នុងផ្នែក C ។